# លោកស ខេង ជំរុញឱ្យគ.ជ.អ.ប បន្តដោះស្រាយបញ្ហាប្រឈម ដើម្បីធានាដល់ការជំរុញប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ



*លោកស ខេង ជំរុញឱ្យ គ.ជ.អ.ប បន្តដោះស្រាយបញ្ហាប្រឈម ដើម្បីធានាដល់ការជំរុញប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ*

**ភ្នំពេញ** : លោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានជំរុញឱ្យលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បន្តខិតខំដោះស្រាយបញ្ហាប្រឈម ដើម្បីធានាដល់ការជំរុញឱ្យកិច្ចដំណើរការកំណែទម្រង់សម្រេចបាននូវគោលដៅរយៈពេលវែង ដែលបានកំណត់នៅក្នុងច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិ។

លោក ស ខេង បានជំរុញបែបនេះ នៅថ្ងៃទី៣០ខែឧសភា ឆ្នាំ២០១៣ បានបើកកិច្ចប្រជុំលើកទី៨ ដើម្បីពិភាក្សា និងអនុម័តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៃការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលបានប្រព្រឹត្តធ្វើនៅស្តីការក្រសួងមហាផ្ទៃ។

បញ្ហាប្រឈមសំខាន់ៗទាំង នោះរួមមាន : ការកែលម្អប្រព័ន្ធគ្រប់គ្រង គ.ជ.អ.ប មានប្រសាសន៍នៅក្នុងពិធី បើកកិច្ចប្រជុំលើកទី៨នេះថាក្នុងការគាំទ្រដល់កិច្ចដំណើរការនៃកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការរបស់ រាជរដ្ឋាភិបាលយើងសម្រេចបាននូវ សមិទ្ធផលសំខាន់ៗជាច្រើននាពេលថ្មីៗ កន្លងមកនេះ ដែលជាមូលដ្ឋានគ្រឹះដ៏ រឹងមាំសម្រាប់បន្តជំរុញកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ។

សមិទ្ធផលទាំងនោះរួមមាន ការរៀបចំការកែសម្រួល និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានចាំបាច់ថ្មីៗជាច្រើន ដើម្បីផ្តល់នូវក្របខ័ណ្ឌគតិយុត្តិ និងគោលការណ៍សំខាន់ៗសម្រាប់អនុវត្តនូវផែនការអនុវត្តន៍បីឆ្នាំដំបូង នៃកម្មវិធីជាតិកំពុងស្ថិតនៅលើរបត់ផ្លូវជាគន្លឹះដ៏សំខាន់មួយនៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

លិខិតបទដ្ឋានគតិយុត្តិដែលបានរៀបចំ និងបានកែសម្រួលទាំងនោះរួមមានដូចជា អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ក្រុង ស្រុក ប្រកាស

ជាលទ្ធផល គ.ជ.អ.ប បានអនុម័តឯកសារសំខាន់ៗដូចជា: សេចក្តីព្រាងអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ ។ សេចក្តីព្រាងគោលនយោបាយស្តីពីការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ។ សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្ទេរធនធាន និងថវិការដ្ឋជូនមូលនិធិឃុំសង្កាត់ ។ សេចក្តីព្រាងសេចក្តីណែនាំស្តីពីការពិនិត្យ មើលឡើងវិញនូវមុខងារសម្រាប់ការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោម ជាតិ។ ឯកសារទស្សនទានស្តីពីការអនុវត្តន៍សាកល្បងនៃការផ្ទេរមុខងារ ជាក់លាក់មួយចំនួនក្នុងវិស័យ សុខាភិបាល។

លោក ស ខេង ក៏បានបញ្ជាក់ពីបញ្ហាទាក់ទងនឹងមុខងារជលផល ដោយបានស្នើ ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ធ្វើការណែនាំ

មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំលិខិតបទដ្ឋានចាំបាច់នានា ដើម្បីជំរុញដល់ការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក និងមូលនិធិក្រុងស្រុក ការជំរុញកិច្ចដំណើរ ការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការជំរុញដល់ការពង្រឹងការអនុវត្តន៍ការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើប្រតិភូកម្មការផ្តល់សេវារដ្ឋបាលរបស់ក្រសួងស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ល។

លោកឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធានអន្តរក្រសួង ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ,ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដើម្បីបើកផ្លូវឱ្យមានការធ្វើប្រតិភូកម្មនូវសិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ ព្រមទាំងអនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំពាក់ព័ន្ធជាច្រើនផ្សេងទៀត ដែលត្រូវបានរៀបចំក្នុងលក្ខណៈជាសេចក្តីព្រាងនៅឡើយ។

បន្ថែមទៀតដើម្បីឱ្យប្រធានខណ្ឌរដ្ឋបាលព្រៃឈើ និងប្រធានខណ្ឌរដ្ឋបាលជលផលធ្វើការជាមួយគណៈអភិបាលរាជធានី ខេត្ត ពីព្រោះយោងតាម ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ខេត្តក៏ទទួលខុសត្រូវក្នុងការការពារព្រៃឈើ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ ។ លោកក៏បានជំរុញឱ្យមន្ត្រីដែលមានបទពិសោធន៍អនុវត្តការងារ និងមន្ត្រីពាក់ព័ន្ធនានាត្រូវបង្កើនកិច្ចពិភាក្សា ពិសេសការពិភាក្សាបញ្ហាប្រាក់របបលើការចុះអនុវត្តការងារ និងប្រាក់រដ្ឋបាលនៅក្នុងអំឡុងពេលបំពេញការងារនៅថ្នាក់ក្រោមជាតិ ហើយត្រូវធ្វើយ៉ាងណាឱ្យមានតម្លាភាព ៕ **តារារិទ្ធ**